ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jan-2013, 14:10
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (២២)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (22)

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Judge Florence Ndepele Mwachande MUMBA
ចៅក្រម សោម សេរីវុឌ្ឍ
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# ដីកាបង្គាប់ឲ្យដាក់ឯកសារលេខ (E238/9/2/1) នៃបណ្តឹងសាទុក្ខរបស់អៀង សារី ជាសាធារណៈដោយមានការកោសលុប

**សហព្រះរាជអាជ្ញា**
ជា លាង

**ជនជាប់ចោទ**
អៀង សារី

Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី** | **សហមេធាវីជនជាប់ចោទ អៀង សារី**

ពេជ អង្គ | អាង ឧត្ដម

Elisabeth SIMONNEAU FORT | Michael G. KARNAVAS

1. **អង្គជំនុំជម្រះតុលាការកំពូល** ("អ.ជ.ត.ក") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") សម្រាប់កាត់ក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ បានទទួល "បណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការតែងតាំងអ្នកជំនាញបន្ថែម ដើម្បីវាយតម្លៃសម្បទារបស់គាត់" ដែលបានដាក់កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣ ("បណ្ដឹងសាទុក្ខ")[1]។

2. នៅពេលដែលដាក់បណ្ដឹងសាទុក្ខ មេធាវីការពារក្ដី អៀង សារី ("មេធាវីការពារក្ដី") បានស្នើសុំឲ្យចាត់ថ្នាក់ឯកសារនេះជាប្រភេទសាធារណៈ[2]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បណ្ដឹងសាទុក្ខនេះបានបង្ហាញព័ត៌មានដែលមាននៅក្នុងឯកសារសម្ងាត់បំផុតមួយ ទាក់ទិននឹងសុខភាពរបស់ អៀង សារី[3]។

3. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ជនគ្រប់រូបដែលមានសិទ្ធិពិនិត្យមើលព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ និងមិនត្រូវប្រព្រឹត្តក្នុងរូបភាពណា ដែលនឹងបណ្ដាយឲ្យលេចព្ញព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុតដោយគ្មានការអនុញ្ញាតនោះទេ[4]។ អាស្រ័យហេតុនេះ ឯកសារណាមួយដែលត្រូវបានស្នើសុំដាក់នោះ ត្រូវដាក់ចំណាត់ប្រភេទដែលបានស្នើសុំនោះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ ហើយភាគី

---

[1] ឯកសារលេខ E238/9/2/1។

[2] បណ្ដឹងសាទុក្ខ ទំព័រដំបូង។

[3] បណ្ដឹងសាទុក្ខ ជើងទំព័រ ១០៥ *និង* ១០៧ *ដកស្រង់ចេញពី* របាយការណ៍អ្នកជំនាញស្ដីអំពីលោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (E238) ឯកសារលេខ E238/4 សម្ងាត់បំផុត ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("E238/4")។

[4] មាត្រា ៨.១ នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង វិសោធនកម្មលើកទី១ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ ("សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ")។ *សូមមើលផងដែរ* វិធាន ២២(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")។

ដាក់ឯកសារត្រូវតែធានាថា ឯកសារដែលពួកគាត់ស្នើសុំឱ្យដាក់ចំណាត់ប្រភេទជាឯកសារ "សាធារណៈ" មិនត្រូវមានព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុតនោះទេ[5]។

4. ការពិតគឺថា ព័ត៌មានទាក់ទងនឹងលោក អៀង សារី ខ្លួនឯង មិនបានផ្តល់សិទ្ធិឱ្យមេធាវីការពារក្តីលាតត្រដាង ក្នុងរបៀបណាមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់ចំណាត់ប្រភេទនៃឯកសារដែលត្រូវបានកំណត់ដោយតុលាការរួចហើយនោះទេ[6]។ អនុលោមតាមមាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ អង្គជំនុំជម្រះតុលាការកំពូល ចាត់ចំណាត់ប្រភេទបណ្តឹងសាទុក្ខនេះឡើងវិញ ថាជាប្រភេទឯកសារសម្ងាត់បំផុត[7]។

5. ដើម្បីរក្សានូវតម្រូវការទូទៅដើម្បីធានាអំពីតម្លាភាពនៃកិច្ចដំណើរការនីតិវិធី សារណាទាំងអស់ដែលដាក់នៅចំពោះមុខ អ.វ.ត.ក ត្រូវតែជាប្រភេទឯកសារសាធារណៈ លើកលែងតែមានមូលហេតុពិសេស ដើម្បីចាត់ប្រភេទផ្នែកណាមួយ ឬទាំងមូល នៃសារណាទាំងនោះ ជាប្រភេទព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត[8]។ ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភាគីដាក់ឯកសារ ដែលស្នើសុំឱ្យចាត់ជាប្រភេទឯកសារសម្ងាត់ ឬសម្ងាត់បំផុត គួរតែដាក់សំណៅកោសលុប

---

[5] មាត្រា ៣.១៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអ.វ.ត.ក វិសោធនកម្មលើកទី ៨ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")។

[6] *សូមប្រៀបធៀប* បណ្តឹងសាទុក្ខ ជើងទំព័រលេខ ៣៩ *និង* ១០៦ *ដោយយោងលើ* កំណត់ហេតុសុខភាព មុនពេលសវនាការ ឯកសារលេខ E1/147.2 ឯកសារសម្ងាត់បំផុត ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ និងការបកប្រែជាភាសាអង់គ្លេស បានដាក់នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ ("ឯកសារលេខ E1/147.2")។ ផ្ទុយគ្នានឹងសម្រង់ដែលបង្ហាញឱ្យឃើញដោយផ្ទាល់ពីឯកសារ E238/4 អៀង សារី គ្រាន់តែសំអាងលើឯកសារលេខ E1/147.2 ដែលអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថាអាចទទួលយកបានជាទូទៅ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ចម្លើយរបស់ អៀង សារី ដែលលើកឡើងថា ឯកសារលេខ E1/147.2 "ត្រូវបានចាត់ប្រភេទជាឯកសារសម្ងាត់បំផុត ទោះបីជា លោក អៀង សារី បានជូនដំណឹងថា បញ្ហាសុខភាពរបស់គាត់ គួរតែត្រូវបានផ្សព្វផ្សាយជាសាធារណៈក៏ដោយ"។ *សូមមើល* បណ្តឹងសាទុក្ខ ជើងទំព័រ ៣៩ *និង* ១០៦ *ដោយយោងលើ* ការយល់ព្រមរបស់លោក អៀង សារី ចំពោះការពិភាក្សាជាសាធារណៈលើបញ្ហាសុខភាពរបស់គាត់ ឯកសារលេខ E1/142.2 ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការលើកឡើងបែបនេះ មិនអាចទាត់ចោលលក្ខខណ្ឌតម្រូវជាធរមានក្នុងការចាត់ចំណាត់ថ្នាក់ឯកសារសាជាថ្មី។ *សូមមើល* មាត្រា ៩ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។ *សូមមើលខាងក្រោមផងដែរ* កថាខណ្ឌ៥។

[7] *សូមមើលផងដែរ* មាត្រា ៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។

[8] *ប្រៀបធៀប* វិធាន ២៩(៤)(ឃ), ៥៤, ៥៦(២)(ក), ៦៦(១), ៧៨, ៧៩(៦), ១០២(១), ១០៩(១) *និង* ១១៣(៤) នៃវិធានផ្ទៃក្នុង។ មាត្រា ១.២, ៤-៦ និង៩.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។

ជាសាធារណៈនៃឯកសារនោះ ឲ្យបានសមស្រប[9]។ ស្រដៀងគ្នានេះដែរ ភាគីស្នើសុំឲ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញពីប្រភេទឯកសារសាធារណៈ ទៅជាប្រភេទឯកសារសម្ងាត់ ឬសម្ងាត់បំផុត គួរតែដាក់សំណៅកោសលុបជាសាធារណៈ ឲ្យបានសមស្រប[10]។ នៅពេលមានការចាត់ប្រភេទឯកសារឡើងវិញពីប្រភេទឯកសារសាធារណៈ ទៅជាប្រភេទឯកសារសម្ងាត់ ឬសម្ងាត់បំផុត ដែលជាឯកសារចេញពីសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ភាគីនានាដែលពាក់ព័ន្ធ គួរតែត្រូវបានណែនាំឲ្យដាក់សំណៅកោសលុបជាសាធារណៈនៃឯកសារនោះ ឲ្យបានសមស្រប[11]។

6. ផ្អែកតាមសំអាងហេតុខាងលើនេះ ***អង្គជំនុំជម្រះតុលាការកំពូល*** ដោយអនុលោមតាមវិធាន ៣៥(២)(ក) និងវិធាន ៣៥(១)(ក) នៃវិធានផ្ទៃក្នុង និងមាត្រា៩.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ៖

**បង្គាប់** មេធាវីការពារក្តីឲ្យដាក់សំណៅកោសលុបជាសាធារណៈនៃបណ្តឹងសាទុក្ខ មិនឲ្យលើសពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣។

**បង្គាប់** មេធាវីការពារក្តីឲ្យធានាថា ការកែប្រែចំពោះសំណៅសម្ងាត់បំផុតនៃបណ្តឹងសាទុក្ខត្រូវកំហិតត្រឹមតែការកោសលុបដែលចាំបាច់ទៅលើព័ត៌មានសម្ងាត់បំផុតតែប៉ុណ្ណោះ ដូចជាសម្រង់ដែលមាននៅត្រង់ជើងទំព័រ ១០៥ និង ១០៧ នៃបណ្តឹងសាទុក្ខ និងមិនត្រូវបន្ថែម ឬលុបព័ត៌មាន ឬកែប្រែត្រង់ចំណុចណាផ្សេងទៀតនោះទេ។

**បង្គាប់** មេធាវីការពារក្តីដាក់សញ្ញាសម្គាល់ឲ្យបានច្បាស់លើផ្នែកដែលខ្លួនបានកោសលុប នៅក្នុងអត្ថបទនៃសំណៅបណ្តឹងសាទុក្ខជាសាធារណៈ ឬដាក់ឧបសម្ព័ន្ធសម្ងាត់ទៅនឹងបណ្តឹងសាទុក្ខដោយបញ្ជាក់អំពីចំណុចដែលខ្លួនបានកោសលុបទាំងអស់។ និង

---

[9] *ប្រៀបធៀប* មាត្រា ៣.១៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ *និង*មាត្រា ៩.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។

[10] *ប្រៀបធៀប* មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ *និង*មាត្រា ៩.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។

[11] *ប្រៀបធៀប* មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ *និង*មាត្រា ៩.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។ *សូមមើលផងដែរ* មាត្រា ៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។

**រំឮក** មេធាវីការពារក្ដីឲ្យយកចិត្តទុកដាក់ឲ្យកាន់តែខ្លាំង ក្នុងការមិនផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត នៅពេលដាក់ឯកសារណាមួយនាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**